ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
********

តុលាការកំពូល
សភាផ្នែករដ្ឋប្បវេណី
សំណុំរឿងរដ្ឋប្បវេណី
លេខ: ១៣៩
ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១
សាលដីកា
លេខ : ៧
ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២

**នាមនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២ ដោយមានសមាសភាពដូចតទៅ ៖

១. ឯកឧត្តម ឌិត មុន្ទី ជាប្រធាន
២. លោក ស៊ិន ឌឹម ជាចៅក្រម-របាយការណ៍
៣. លោក ជីវ កេង ជាចៅក្រម
៤. លោក សោម សិរីវឌ្ឍ ជាចៅក្រម
៥. លោក ប្រាក់ គឹមសាន ជាចៅក្រម
៦. លោក ឈឹម ស៊ីផល ជាចៅក្រម
៧. លោក យស់ សូខឿន ជាចៅក្រម
៨. លោក គង់ ភីរុណ ជាចៅក្រម
៩. លោក ប៉ែន សារឿន ជាចៅក្រម

ក្រឡាបញ្ជី
កញ្ញា ហុក សុខផុល
តំណាងមហាអយ្យការ
លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ០៩(ឈ)ចុះថ្ងៃទី៣០-មករា-២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៧២ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ។

- រវាងដើមចោទអ្នកស្រីវួច អេង អាយុ៤៨ ជាតិខ្មែរ របរលក់ដូរ ទីលំនៅសព្វថ្ងៃផ្ទះលេខ៥៦អឺសូឡ ផ្លូវ១២៦ ក្រុម១៧ សង្កាត់ផ្សារថ្មី២ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។ មេធាវី គ្មាន ។

- និងចុងចម្លើយឈ្មោះលោកសេង គឹមស៊ុយ អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរវេជ្ជបណ្ឌិត ទីលំនៅសព្វថ្ងៃផ្ទះលេខ១៣៦ ផ្លូវលេខ១៣ សង្កាត់ផ្សារកណ្តាល១ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។ មេធាវី គ្មាន ។

កម្មវត្ថុ : ប្តឹងសុំលែងលះ ។

បានឃើញបណ្តឹងសាទុក្ខលេខ៥៤ ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០១ របស់ឈ្មោះ សេង គឹមស៊ុយ និង បណ្តឹងសាទុក្ខលេខ៧០ ចុះថ្ងៃទី១២_៣_២០០១របស់អ្នកស្រីនាងរួច អេង ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១៣៩ ចុះថ្ងៃទី១៨_៥_២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៨_១១_៩៨របស់ដើមចោទឈ្មោះអ្នកស្រីរួច អេង ប្តឹងសុំលែងលះប្តី ឈ្មោះសេង គឹមស៊ុយ ដោយសំអាងហេតុថា៖តាំងពីរៀបការជាប្តីប្រពន្ធមកខ្លួន ប្តីខ្លួនមិនជួយរកស៊ីចិញ្ចឹមកូន គិតតែលេងល្បែងស៊ីសងរករឿងវាយដំខ្លួននិងកូនៗ គ្មានលោះថ្ងៃណាឡើយ។ នៅថ្ងៃទី៣០_៦_៩៧ប្តីខ្លួនបានចាកចេញពីផ្ទះ ព្រមទាំងវាយដំខ្លួន និង កូនទាំងបួនហើយបានពុះទូរប្រមូលយកមាសប្រាក់ ប្លង់ផ្ទះទាំងពីរល្វែងប្លង់ដីយកទៅបញ្ចាំគេ ដើម្បីចូលកាស៊ីណូ ហ្វូលីដេ ។ ក្រោយមកខ្លួនបានខ្ចីលុយគេ យកទៅលោសយកប្លង់ផ្ទះ និង ប្លង់ដីមកវិញ ។

បានឃើញដីការសំរេច របស់តុលាការក្រុងភ្នំពេញលេខ៤២(ក)ចុះថ្ងៃទី១៩_១១_៩៨ ដែលមានខ្លឹមសារដូចតទៅ ៖

១_ ទទួលពាក្យបណ្តឹងចុះថ្ងៃទី ១៨_១១_៩៨ របស់ដើមចោទឈ្មោះនាងរួច អេង ប្តឹងសុំហាមឃាត់មិនឱ្យឈ្មោះសេង គឹមស៊ុយ លក់ដូរ ផ្ទេរសិទ្ធិ បញ្ចាំឬធ្វើអំណោយទៅអ្នកដទៃនូវដីឡូតិ៍លេខ១៨៤ ផ្លូវ៦៣ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ ផ្ទះលេខ១៣៦ ផ្លូវ១៣ សង្កាត់ផ្សារកណ្តាល១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ និងផ្ទះលេខ៥៦អឺសូន្យ ផ្លូវ១២៦ ក្រុម១៧ សង្កាត់ផ្សារថ្មី ខណ្ឌដូនពេញ ក្រុងភ្នំពេញ ជាបណ្តោះអាសន្ន នោះទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២_ ហាមឃាត់មិនឱ្យឈ្មោះសេង គឹមស៊ុយ លក់ដូរ ផ្ទេរសិទ្ធិ បញ្ចាំឬធ្វើអំណោយទៅអ្នកដទៃ នូវដីឡូតិ៍លេខ១៨៤ ផ្លូវ៦៣ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ ផ្ទះលេខ១៣៦ ផ្លូវ១៣ សង្កាត់ផ្សារកណ្តាល១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ និងផ្ទះលេខ៥៦អឺសូន្យ ផ្លូវ១២៦ ក្រុម១៧ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ជាបណ្តោះអាសន្នសិនរង់ចាំតុលាការសំរេចដល់រឿងអង្គសេចក្តីចប់ជាស្ថាពរ ។

៣_ បង្គាប់ឱ្យឈ្មោះនាងរួច អេង បង់ប្រាក់ប្រដាប់ក្តី២.០០០រៀល ។

៤_ បើគូភាគីមិនសុខចិត្តនិងដីកានេះ មានសិទ្ធិប្តឹងទាស់ក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃបានទទួលដំណឹងពីដីកានេះតទៅ ។

តុលាការក្រុងភ្នំពេញបានចេញដីកាសំរេចកិច្ចការប្រញាប់លេខ០២(ដ)ចុះថ្ងៃទី១១_០១_៩៩ ដែលមានខ្លឹមសារ ដូចតទៅ ៖

១_ ទទួលពាក្យបណ្ដឹងហាមឃាត់ចុះថ្ងៃទី០៤_០១_៩៩របស់ដើមចោទឈ្មោះសេង គីមស៊ុយ ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

២_ ហាមឃាត់ឈ្មោះនាង វួច អេង មិនឱ្យជួលលក់ដូរបញ្ចាំផ្ទេរកម្មសិទ្ធិ ឬធ្វើអំណាចដល់អ្នកដទៃនូវតូបលេខ៩៣ស្ថិតក្នុងផ្សារធំថ្មី ប្រាក់តំកល់ក្នុងធនាគារផលិតកម្មជាចំនួន ៥០.០០០$ក្នុងវិញ្ញាបនប័ត្រចុះថ្ងៃទី០៨_៧_៩៨និងប្រាក់ចំនួន១០០.០០០$ ក្នុងវិញ្ញាបនប័ត្រចុះថ្ងៃទី១២_១២_៩៨ និងប្រាក់ចំនួន១៥០.០០០$ដែលកំពុងគ្រប់គ្រងដោយនាងវួច អេង ទុកជាបណ្ដោះអាសន្នរង់ចាំតុលាការសំរេចដល់អង្គសេចក្ដី ។

៣_ បង្គាប់ឱ្យដើមចោទឈ្មោះសេង គីមស៊ុយ បង់ប្រាក់ប្រដាប់ក្ដីចំនួន ២.០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ដែលដើមចោទបានបង់ទុករួចជាស្រេច ។

៤_ ដីកាសំរេចនេះ មានអនុភាពយកទៅអនុវត្តភ្លាមៗទោះជាមានបណ្ដឹងឧទ្ធរណ៍ក៏ដោយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៨៩(ក)ចុះថ្ងៃទី១៦_៦_៩៩ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារដូចតទៅ ៖

១_ ទទួលពាក្យបណ្ដឹងចុះថ្ងៃទី១៨_១១_៩៨របស់ដើមចោទឈ្មោះនាងវួច_អេង ទុកជាត្រឹមត្រូវ តាមទំរង់និងគតិច្បាប់ ។

២_ ឱ្យឈ្មោះនាងវួច អេង និងឈ្មោះសេង គីមស៊ុយ ដាច់សមគ្គសង្វាស តាមការព្រមព្រៀងគ្នា ចាប់ពីថ្ងៃនេះតទៅ ។

៣_ ឱ្យឈ្មោះនាងវួច អេង ស្ថិតនៅជាភាពមេម៉ាយចំនួន៣០០ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៤_ ប្រគល់កូនឈ្មោះ សេង សុធី ភេទប្រុស អាយុ១៨ឆ្នាំ សេង សុធារ៉ា ភេទប្រុស អាយុ១៦ឆ្នាំ សេង សុគន្ធារិទ្ធិ ភេទប្រុស អាយុ១៤ឆ្នាំ និង ឈ្មោះ សេង សុគន្ធារី ភេទស្រី អាយុ១២ឆ្នាំ ឱ្យទៅឈ្មោះនាងវួច អេង គ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាចាប់ពីថ្ងៃនេះតទៅនិងបង្គាប់ឱ្យឈ្មោះសេង គីមស៊ុយ បង់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព រហូតដល់កូននីតិភាព ឱ្យទៅឈ្មោះនាងវួច អេង ។

៥_ បែងចែកទ្រព្យសម្បត្តិរួមមានដីឡូតិ៍លេខ១៨៤ ផ្លូវលេខ៦៣ សង្កាត់បឹងកេងកង១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ផ្ទះលេខ១៣៦អីស្មូឡ អី១ អី២ ផ្លូវលេខ១៣ សង្កាត់

ផ្សារកណ្តាល១ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ផ្ទះលេខ៥៦អឺសូន្យ ផ្លូវ១២៦ សង្កាត់ផ្សារថ្មី២ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ និងតូបលក់មាសលេខ៩៣ នៅផ្សារធំថ្មីឱ្យទៅឈ្មោះវួច អេង ចំនួន៣/៤និងឱ្យឈ្មោះសេង គឹមស៊ុយ១/៤តាមតម្លៃជាក់ស្តែង តែទ្រព្យសម្បត្តិទាំងនោះ ត្រូវដកសងឱ្យទៅឈ្មោះឌី ចាន់ធី ចំនួន១៦.០០០$ ដែលឈ្មោះនាងវួច អេង បានខ្ចីកាលពីថ្ងៃ០៩_១២_៩៧ ។

៦_ រំលាយចំណងអាពាហ៍ពិពាហ៍របស់ឈ្មោះនាងវួច អេង និង ឈ្មោះសេង គឹមស៊ុយ ចាប់ពីថ្ងៃនេះតទៅ ។

៧_ បង្គាប់ឱ្យឈ្មោះសេង គឹមស៊ុយ បង់ប្រាក់ប្រដាប់ក្តី៧.០០០រៀល គឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្វីង១.៨០០រៀល វង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០រៀល វង្វាន់សាក្សី២០០រៀលវង្វាន់អ្នកប្រគល់ដីកាកោះ៣.០០០រៀលប្រាក់នេះ បានកាត់យក ពីប្រាក់៧.០០០រៀល ដែលដើមចោទបានបង់ទុកជាស្រេច ។ កាលបើហួសកំណត់ឧទ្ធរណ៍ហើយ បង្គាប់ឱ្យឈ្មោះសេង គឹមស៊ុយ សងប្រាក់៧.០០០រៀល ទៅដើមចោទវិញ ។

៨_ សាលក្រមនេះជំនុំជំរះនិងប្រកាសជាសាធារណៈ ចំពោះមុខគូភាគីសំរេចបើកផ្លូវឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣៩(ក) ចុះថ្ងៃទី២៤_៦_៩៩របស់លោកសេង គឹមស៊ុយនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧២៨ ចុះថ្ងៃទី៣០_៩_៩៩ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារដូចតទៅ ៖

១_ ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃ២៤_៦_៩៩របស់ឈ្មោះសេង គឹមស៊ុយ ។

២_ មិនទទួលពាក្យបណ្តឹងចុះថ្ងៃទី១០_៨_៩៩របស់ឈ្មោះងៃ គឹមឆន និងពាក្យចុះថ្ងៃទី១៥_៨_៩៩របស់ឈ្មោះសេង លឹមខេង ដោយផ្ទុយពីទំរង់និងគតិច្បាប់ ។

៣_ តំកល់សាលក្រមរដ្ឋប្បវេណីលេខ៤៩(ក)ចុះថ្ងៃទី១៦_៦_៩៩របស់តុលាការក្រុងភ្នំពេញទុកជាបានការ ប៉ុន្តែលើកលែងចំណុចទី៤ និងទី៥ ត្រូវកែប្រែជាថ្មី ។

៤_(ក)ប្រគល់កូនឈ្មោះសេង សុធារ៉ា ភេទប្រុស អាយុ១៦ឆ្នាំសេង សុគន្ធារិទ្ធិ ភេទប្រុស អាយុ១៤ឆ្នាំ និងឈ្មោះសេង សុគន្ធារី ភេទស្រី អាយុ១២ឆ្នាំ តាមសំណូមពរ របស់កូនទាំងបីនាក់ ទៅឱ្យឈ្មោះនាងវួច អេង គ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សារហូតដល់កូនទាំងបីនាក់នេះក្លាយជានីតិជន ។

(ខ) បង្គាប់ឱ្យឈ្មោះសេង គឹមស៊ុយ បង់ប្រាក់អាហារកិច្ចចិញ្ចឹមកូនទាំងបីនាក់នេះ តាមរបបរដ្ឋកំណត់ រហូតដល់ កូនក្លាយជានីតិជនទៅឱ្យឈ្មោះនាងវួច អេង ។

៥- បែងចែកប្រាក់ដែលតម្កល់ទុកនៅធនាគារឥណទាន កម្ពុជាជាពីរចំណែកស្មើៗគ្នា រវាងប្ដីនិងប្រពន្ធ បើសិនជាមានបន្សល់ទុកក្នុងធនាគារ ។

៦(ក) ប្រគល់ផ្ទះលេខ១៣៦អឺស្ទួឡ អឺ១ អឺ២ ផ្លូវលេខ១៣ សង្កាត់ផ្សារកណ្ដាលទី១ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ទាំងមូល ទៅឱ្យលោកសេង គីមស៊ុយ កាន់កាប់និងគ្រប់គ្រង ជាកម្មសិទ្ធិ នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

ខ- ប្រគល់ផ្ទះលេខ៥៦អឺស្ទួឡ ផ្លូវលេខ១២៦ សង្កាត់ផ្សារថ្មីទី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ទៅឱ្យឈ្មោះនាងវួច អេង កាន់កាប់និងគ្រប់គ្រងជាកម្មសិទ្ធិនៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

គ- បែងចែកតូបលក់មាសលេខ៩៣ ស្ថិតនៅផ្សារធំថ្មីនិងដីឡូតិ៍លេខ១៨៤ ផ្លូវលេខ៦៣ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ ជាតម្លៃជាពីរចំណែកស្មើៗគ្នា ។

៧- ទុកសិទ្ធិឱ្យឈ្មោះសេង លីមខេង និងឈ្មោះឆៃ គីមឆន ប្ដឹងទាមទារប្រាក់ពីរឈ្មោះសេង គីមស៊ុយ និងឈ្មោះនាងវួច អេង ទៅតុលាការថ្នាក់ក្រោម តាមផ្លូវច្បាប់ ។

៨- សំរេចកាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀលគឺពន្ធចុះបញ្ជីក្ដី និងពន្ធហ៊ីង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ៥.០០០រៀល និងលើអាជ្ញាធរ តុលាការ៥.០០០រៀល សរុប១៣.០០០រៀល ។

៩- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៤២៦ ចុះថ្ងៃទី០១-១០-៩៩របស់អ្នកស្រីវួច អេង មិនសុខចិត្តនឹងសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១២៥ ចុះថ្ងៃទី២៩-៦-២០០០របស់តុលាការកំពូលដែលមានខ្លឹមសារដូចតទៅ ៖

១- ទទួលបណ្ដឹងសាទុក្ខលេខ៤២៦ចុះថ្ងៃទី០១-១០-៩៩ របស់អ្នកស្រីនាងវួច អេង ទុកជាត្រឹមត្រូវតាមទំរង់នឹងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៧២៨ ចុះថ្ងៃទី៣០-៩-៩៩របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣៨៩ ចុះថ្ងៃទី០៦-១២-៩៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលអ្នកស្រីនាងរួច អេង បានបង់រួចហើយគឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្មឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប ១៩.០០០រៀល ហើយត្រូវឱ្យលោកសេង គីមស៊ុយ សងប្រាក់ចំនួន១៩.០០០រៀល នេះទៅអ្នកស្រី នាងរួច អេង ។

៥- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៩-៦-២០០០។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៩១(ឈ) ចុះថ្ងៃទី៣០-០១-២០០១ របស់សាលា ឧទ្ធរណ៍សំរេចលើកទី២ ដែលមានខ្លឹមសារដូចតទៅ ៖

១- ទទួលជំនុំជំរះរឿងរដ្ឋប្បវេណីលេខ៧២ចុះថ្ងៃទី១៩-៩-២០០០របស់សាលា ឧទ្ធរណ៍ឡើងវិញ តាមអំណាចសាលដីកាលេខ១២៥ ចុះថ្ងៃទី២៩-៦-២០០០របស់តុលាការកំពូល ។

២- ឱ្យឈ្មោះរួច អេង និងសេង គីមស៊ុយ ដាច់សមគ្គសង្វាសពីគ្នាចាប់ពី ថ្ងៃនេះតទៅ តាមការព្រមព្រៀង ។ (មាត្រា៤០នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ) ។

៣- ប្រគល់កូន០៣នាក់ឱ្យទៅនាងរួច អេង គ្រប់គ្រងចិញ្ចឹមថែរក្សាបីបាច់ រហូតដល់កូនទាំង០៣នាក់ ក្លាយជានីតិជនមាន ៖ ឈ្មោះសេង សុធារ៉ា ភេទប្រុស អាយុ១៦ឆ្នាំ ឈ្មោះសេង សុកន្ធារិទ្ធ ភេទប្រុស អាយុ១៤ឆ្នាំ ឈ្មោះសេង សុគន្ធារី ភេទស្រី អាយុ១៣ឆ្នាំ ។

៤- ប្រគល់ផ្ទះលេខ៥៦អឺសួន្យ ផ្លូវ១២៦ សង្កាត់ផ្សារថ្មី២ ខ័ណ្ឌដូនពេញ ឱ្យទៅនាងរួច អេង កាន់កាប់និងគ្រប់គ្រងជាកម្មសិទ្ធិ និងផ្ទះលេខ១៣៦អឺសួន្យ-អឺ១-អឺ២ ផ្លូវលេខ១៣ សង្កាត់ផ្សារកណ្តាលទី១ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ឱ្យទៅឈ្មោះសេង-គីមស៊ុយ កាន់កាប់គ្រប់គ្រង ជាកម្មសិទ្ធិតទៅតាមការព្រមព្រៀងរបស់គូភាគី ។

៥- ប្រគល់តូបលេខ៩៣ស្ថិតនៅផ្សារធំថ្មីឱ្យទៅឈ្មោះសេង គីមស៊ុយ កាន់ កាប់តទៅ ។

៦- ប្រគល់ដីឡូត៍លេខ១៨៤ ផ្លូវលេខ៦៣ សង្កាត់បឹងកេងកងទី១ ខ័ណ្ឌ ចំការមន ក្រុងភ្នំពេញ ឱ្យឈ្មោះរួច អេង កាន់កាប់គ្រប់គ្រងដើម្បីជាប្រយោជន៍កូនៗ ទាំង៣នាក់ ដោយពុំចាំបាច់ឱ្យឈ្មោះសេង គីមស៊ុយ បង់ប្រាក់អាហារកិច្ចឡើយ ។

៧- រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល គឺពន្ធចុះ បញ្ជីក្តី និងពន្ធហ្មឹងចំនួន២.៩៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០រៀល ចំណាយក្នុងកិច្ច ប្រគល់ដីកាកោះ៥.០០០រៀល ចំណាយលើអាជ្ញាធរតុលាការ៥.០០០រៀល សរុប១៣.០០០រៀល ។

៨_ សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តីបើកផ្លូវប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ៥៤ ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០១របស់ឈ្មោះសេង គីមស៊ុយ និងបណ្តឹងសាទុក្ខលេខ៧០ចុះថ្ងៃទី១២_៣_២០០១របស់អ្នកស្រីនាងវួច អេង ។

បានឃើញសារណាការពាររបស់ឈ្មោះនាងវួច អេង ចុះថ្ងៃទី២៤_មេសា_២០០០។

បានឃើញសារណាឆ្លើយតបរបស់ឈ្មោះសេង គីមស៊ុយ ចុះថ្ងៃទី០២_មករា_២០០០។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអ្យការថា ៖

សាលដីការដ្ឋប្បវេណីលេខ០៩(ឈ)ចុះថ្ងៃទី៣០_០១_២០០១របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែគតិច្បាប់ខុសខ្លះត្រូវខ្លះ ។

សូមក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះសេង គីមស៊ុយ ថា ៖បានជាខ្ញុំបាទប្តឹង ព្រោះខ្ញុំមិនសុខចិត្តនិងសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ត្រង់ចំណុចទី៣ទី៦ប្រាក់១៥ម៉ឺនដុល្លាអាមេរិក ផ្ញើនៅធនាគារនិងប្រាក់ខ្ចីគេ៣៥.០០០$និងមិនសុខចិត្តរឿងដីខ្ញុំបាទសូមជំរាបថាៈប្រាក់១៥ម៉ឺនដុល្លានេះគឺតំកល់នៅធនាគារមិនទាន់បានដកទេ ហើយម្ចាស់ធនាគារត្រូវជាក្មួយបង្កើតរបស់នាងវួច អេង ហើយបានផ្សំគំនិតគ្នាធ្វើលិខិតផ្សេងដកលុយ ឯវិក័យប័ត្រដើម គឺនៅខ្ញុំបាទកាន់កាប់។ ខ្ញុំបាទបានទៅទារយកប្រាក់នេះ តែនាងវួច អេង ជាមិនឱ្យទៅទារ ព្រោះយល់ដល់ក្មួយគេ ខ្ញុំបាទមិនត្រឹមតែទារពីម្ចាស់ធនាគារទេ គឺទារទាំងម្តាយ ម្ចាស់ធនគារទៀតថាឱ្យរកលុយឱ្យខ្ញុំបាទវិញ ។ ចំពោះរឿងដីឡូតិ៍ គឺជាដីអំណោយពីឈ្មោះសេង វៃ បានឱ្យមកខ្ញុំបាទផ្ទាល់ ខ្ញុំបាទសូមទាមទារយកតែម្នាក់ឯង និសូមឱ្យចែកប្រាក់ដែលដាក់នៅធនាគារនោះ ។

បានស្តាប់ចម្លើយរបស់អ្នកស្រីវួច អេង ថា ៖ បានជានាងខ្ញុំប្តឹង ព្រោះឈ្មោះសេង គីមស៊ុយ មិនដែលបានចិញ្ចឹមកូនទេ គិតតែពីដើរលេងខ្ចីលុយគេទៅហ្វូលីដេ ទើបនាងខ្ញុំយកតូបផ្សារថ្មីទៅបញ្ចាំគេដើម្បីយកលុយទៅសងបំណុលគាត់ គាត់គិតតែពីដើរលេងល្បែងស្រីញី មិនបានចិញ្ចឹមកូនទេ កូនទុកឱ្យនាងខ្ញុំចិញ្ចឹមទាំងអស់ ។ នាងខ្ញុំសូមប្រគល់ផ្ទះនៅផ្សារកណ្តាលនោះឱ្យទៅគាត់ដើម្បីឱ្យរាចប់រឿងរ៉ាវ ក្រៅពីនោះនាងខ្ញុំសូមយកទាំងអស់ ព្រោះនាងខ្ញុំជាអ្នកចិញ្ចឹមកូន៤នាក់ ។ចំពោះដីនេះគឺជាដីរួមដែលនាងខ្ញុំបានទៅទិញជាមួយគាត់គឺគ្មានអ្នកណាឱ្យនោះទេ គឺទិញ៩តំលឹងមាស ហើយតូបនៅផ្សារថ្មីក៏នាងខ្ញុំជាអ្នកទិញដែរ ព្រោះខ្ញុំជាអ្នករកស៊ី ។ ចំពោះលុយ១៥ម៉ឺនដុល្លានោះនាងខ្ញុំទទួលស្គាល់ ព្រោះនាងខ្ញុំជាអ្នកយកទៅដាក់ធនាគារ ដើម្បីស៊ីសារទៅលេងអាមេរិកពេលបានវីសារទៅរយៈ

ពេល៦ខែ ឯណោះតែនាងខ្ញុំមិនបាននៅទេ គឺនៅតែជាង១ខែនាងខ្ញុំត្រឡប់មកវិញ ហើយលុយនោះបានដកយកមករកស៊ីរួមគ្នាអស់ហើយ ។ ចំពោះប្រាក់គាត់ខ្ចី៣៥.០០០$ នាងខ្ញុំពុំបានដឹងទេ ព្រោះគាត់ពូកែធ្វើលិខិតក្លែងក្លាយណាស់ ។ នាងខ្ញុំយល់ព្រមតាមការសំរេចរបស់សាលាឧទ្ធរណ៍ទាំងអស់តែសូមទុកតូបនៅផ្សារថ្មី ដើម្បីលក់សងបំណុលដែលគាត់បានខ្ចីគេ ។

បានស្តាប់ចម្លើយរបស់លោកសេង គីមស៊ុយ ថា៖ ខ្ញុំបាទមិនបានក្លែងហត្ថលេខាអ្វីដូចនាងវួច អេង និយាយនោះទេ ហើយខ្ញុំបាទក៏មិនបានទៅពុះទូរអ្វីដែរ ខ្ញុំបាទសុំឱ្យនាងវួច_អេង ស្បថ់នៅចំពោះមុខតុលាការ អំពីរឿងលុយនៅធនាគារ បើនាងហ៊ានស្បថ់នោះខ្ញុំមិនយកសូម្បីតែមួយរៀលទេ ហើយចំពោះរឿងដីបើនាងថា ដីនោះជាដីទិញ តើមានលិខិតស្នាមអ្វីមកបញ្ជាក់ ។

មេធាវី (សេង សឿ) រឿងនេះ ស្ថិតនៅក្នុងរង្វង់គ្រួសារ ហើយរឿងរ៉ាវកូនក្តីខ្ញុំបាទបានបញ្ជាក់រួចហើយ តែខ្ញុំបាទសូមបញ្ជាក់បន្ថែមថា ៖ ចំពោះលុយ១៥ម៉ឺនដុល្លានេះគឺមិនទាន់បានដកពីធនាគារទេ ដោយផ្អែកតាមលិខិតស្នាមដែលមាននៅលើដៃកូនក្តីខ្ញុំបាទ ។ ហើយឈ្មោះស៊ុ វួចជនជាម្ចាស់ធនាគារត្រូវក្មួយរបស់នាងវួច អេង ។

- ចំពោះប្រាក់ជំពាក់គេ៣៥.០០០$គឺក្នុងការរកស៊ីរួមគ្នាក្នុងរង្វង់គ្រួសារ សូមបែងចែកឱ្យនាងទទួលខុសត្រូវ ។

- ចំពោះកូន កូនក្តីខ្ញុំបាទ សូមទទួលខុសត្រូវទាំងអស់នៅចំពោះមុខច្បាប់ ។

- ចំពោះដីគឺជាអំណោយទាន ពីឈ្មោះសេង វ៉ន ឱ្យមកឈ្មោះសេង គីមស៊ុយ ដោយមានលិខិតស្នាមត្រឹមត្រូវ ។

សូមក្រុមប្រឹក្សាមេត្តារកយុត្តិធម៌ ឱ្យកូនក្តីខ្ញុំបាទផង ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយដោះសាររបស់គូភាគីនិងសេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ៥៤ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០១របស់លោកសេង គីមស៊ុយ និងបណ្តឹងសាទុក្ខលេខ៧០ ចុះថ្ងៃទី១២_៣_២០០១របស់អ្នកស្រីវួច អេង ស្ថិតនៅក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

- យល់ឃើញថា សារណាចុះថ្ងៃទី០១_៦_០១និងចុះថ្ងៃទី២៧_៧_២០០១ របស់ចុងចម្លើយដែលលើកឡើងថា ដើមចោទបានឃុបឃិតជាមួយឈ្មោះឌី ចាន់ នី ធ្វើលិខិតក្លែងបន្ទំថ្ងៃ ខែ ឆ្នាំ បំភាន់ តុលាការយកតូបលេខ៩៣ស្ថិតនៅផ្សារធំថ្មីដាក់បញ្ចាំឱ្យឈ្មោះឌី ចាន់នី ក្នុងតម្លៃ ១៦.០០០អាមេរិក យកប្រាក់តែម្នាក់ឯង ។ ប៉ុន្តែតាមការពិតដើមចោទជួលឱ្យឈ្មោះឌី ចាន់នី រយៈពេល៣៦ខែ ក្នុង១ខែ៥០០ដុល្លាអាមេរិកដែលថាតូបនេះខ្លួនបានប្តឹងតុលាការក្រុងភ្នំពេញ ហាមឃាត់កុំឱ្យលក់ដូរបញ្ចាំជួលឬផ្ទេរសិទ្ធិឱ្យអ្នកដទៃរួចហើយ និងថាដើមចោទបំពានលើច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារត្រង់មាត្រា៣៦និង៣៧ដែលស្តីពីការគ្រប់គ្រងចាយវាយឬធ្វើអំណោយឱ្យអ្នកដទៃដែលត្រូវតែមានការព្រមព្រៀងពីសហព័ន្ធទាំង២នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះករណីនេះ ។

- ដីកាសំរេចកិច្ចការប្រញាប់លេខ០២"ជ"ចុះថ្ងៃទី១១_០១_៩៩ធ្វើក្រោយលិខិតដាក់បញ្ចាំចុះថ្ងៃទី០៩_១២_៩៧របស់ដើមចោទ ។

- យល់ឃើញថាលិខិតចុះថ្ងៃទី២៨_០១_៩៧ និង លិខិតចុះថ្ងៃទី១០_២_៩៧របស់ចុងចម្លើយដែលខ្ចីប្រាក់ពីអ្នកស្រីសេង លីមខេង និងពីលោកឆៃ គីមឆន និងលិខិតកិច្ចសន្យាបញ្ចាំតូបចុះថ្ងៃទី៩_១២_៩៧ របស់អ្នកស្រីរួច អេង ឱ្យទៅឈ្មោះ ឌី ចាន់នី ធ្វើឡើងដោយពុំមានការយល់ព្រមពីសហព័ន្ធម្ខាងទៀតដូចគ្នា តុលាការកំពូលពុំគប្បីលើកមកពិចារណាឡើយ ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាប់ថា ចុងចម្លើយមុននឹងចុះចោលប្រពន្ធ និង កូនទៅរស់នៅផ្សេងនោះ បានវាយដំធ្វើបាបប្រពន្ធកូននិងបានពុះទូយកប្រាក់ និងគ្រឿងអលង្ការទៅជាមួយខ្លួនអស់មួយចំនួនដូចមានចម្លើយសាក្សីឈ្មោះកែវ ទ្រី និង ឈ្មោះយិន គីមសេងដែលជាអ្នកបំរើនៅផ្ទះជាមួយនិងជាក្មួយចុងចម្លើយជាភស្តុតាងស្រាប់ ។

- យល់ឃើញថា ចម្លើយសាក្សីឈ្មោះញាណសេង ហុង ជានាយសន្តិសុខធនាគារឥណទានបានឆ្លើយអះអាងថា ដើមចោទបានបើកយកប្រាក់ចេញពីធនាគារតាំងពីថ្ងៃទី០១_៣_៩៥ប្រាកដមែន ។ ដូច្នេះប្រាក់នេះប្តីប្រពន្ធបានបើកយកមកចាយវាយ និង ប្រើប្រាស់តាំងពីនៅក្នុងចំណង - អាពាហ៍ពិពាហ៍នៅឡើយពិតប្រាកដមែន ។

- យល់ឃើញថាដីឡូតិ៍លេខ១៨៤ដែលចុងចម្លើយអះអាងថាជាទ្រព្យអច្ច័យទារទទួលពីឈ្មោះសេង វ៉ន និងនាងរូ ធីលូវ ពីឆ្នាំ១៩៨៩មកជាការពុំត្រឹមត្រូវទេ ពីព្រោះដីនេះបានមកក្នុងរយៈពេលចំណងអាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធនៅឡើយ ហើយក៏ពុំមានភស្តុតាងណាបញ្ជាក់ថាជាទ្រព្យអច្ច័យទានដូចការអះអាងរបស់ចុងចម្លើយឡើយ ។

- យល់ឃើញថាការសំរេចសេចក្តីរបស់សាលាឧទ្ធរណ៍មានលក្ខណៈត្រឹមត្រូវតាមទំរង់និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខតួក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ៥៤ចុះថ្ងៃទី០១-៣-២០០១របស់លោកសេង-គីមស៊ុយ និងបណ្តឹងសាទុក្ខលេខ៧០ចុះថ្ងៃទី១២-៣-២០០១របស់អ្នកស្រីវួច អេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ០៩(ឈ)ចុះថ្ងៃទី៣០-០១-២០០១ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីដែលអ្នកស្រីវួច អេង បានបង់ខ្លួនឯង និងបង់ជួសលោកសេង គីមស៊ុយ នៅតុលាការកំពូលរួមត្រូវ៣៨.០០០រៀល គឺ ៖

- ពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតំរូវឱ្យលោកសេង គីមស៊ុយ សងប្រាក់១៩.០០០រៀល នេះទៅអ្នកស្រីវួច អេង វិញ ។ ប្រាក់សល់ចំនួន១៩.០០០រៀល ប្រគល់ឱ្យអ្នកស្រីវួច អេង វិញ ។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០២៕